# បណ្ដុំទេសនា ៦

ញោម ប៊ិន ឈាង . រស់ រ៉េត ខែត្រ កំពង់ស្ពឺ

ធម្មទេសនា

## បុណ្យកឋិនទាន

# ជំនួយស្មារតី

ធម្មកថិកអង្គថ្មី

ធម្មវិនយោ លោកេ បវត្តតុ

ព្រះធម្មវិន័យ ចូរប្រព្រឹត្តទៅក្នុងលោក

រក្សាសិទ្ធិគ្រប់យ៉ាង បណ្ណាគារត្រៃរតន៍

ព.ស ២៥៤៩ គ.ស ២០០៦

ផ្សាយចេញពី

www.haotrai.com

ចែកជាធម្មទានដោយ

MEKONGNET
CONNECTING YOU ALL

ANANA
Computer
Trusted Service & Quality

# បុណ្យកឋិនទាន

ក្នុងរត្តិភាគ ចំណែកនៃរាត្រីនេះ ខ្ញុំព្រះករុណាអាត្មាភាព បាន ទទួលថេរបញ្ជាអំពីព្រះ មានពុទ្ធាទីជាអម្ចាស់ថិកាចារ្យ ទេសនាក្នុងឱកាស ពេលនេះ ។

ជាបឋម ខ្ញុំព្រះករុណា អាត្មាភាព សូមប្រគេននឹងចំរើនពរ ។

**បញ្ចា ធម្មា** ពរ ៥ ប្រការគឺ:

**អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ**

**អាយុ** សូមអោយមានអាយុវែងយឺនយូរពាប់រយវស្សា ។

**វណ្ណៈ** សូមអោយមានពណ៌សម្បុរកាយល្អ ស្រស់ស្រគាំ ផូរផង់ ព្រោងព្រាយពណ្ណរាយរុងរឿង ។

**សុខៈ** សូមអោយមានសេចក្តីសុខកាយ សប្បាយចិត្តសុខដុមរមនា ។

**ពលៈ** សូមអោយមានកម្លាំងកាយ និងកម្លាំងចិត្ត សតិបញ្ញា ស្មារតីបរិបូណ៌ ។

**បដិភាណៈ** សូមអោយមានប្រាជ្ញាវាងវៃ ឆ្លាតវៃ ឈ្លាសប្រតិពល យល់ហេតុការណ៍បានភ្លាមៗ ។

**វឌ្ឍន្តុ** ពរទាំង ៥ ប្រការនេះ ចូរចំរើនកើតមានដល់ព្រះករុណា **គ្រប់**ព្រះអង្គ និងពុទ្ធបរិស័ទទាំងឡាយ ដែលបានលះគេហដ្ឋាន និមន្ត

និងអញ្ជើញមកសន្និបាតជួបជុំក្នុងទីនេះ ដោយមានបសាទសទ្ធាជ្រះថ្លា ប្រាថ្នាចង់ស្តាប់ និងក្រេបជញ្ជក់យកនូវអត្ថរសនៃធម៌វិសេសទេសនា ដែលមានខ្ញុំព្រះករុណាអាត្មាភាពបានទទួលភារៈជាអ្នកសំដែងដើម្បីស្នង ឆ្លងសទ្ធា របស់លោកអ្នកម្ចាស់ដើមទាន ប្រធានដើមការ ឥស្សរាធិបតី សាមីដើមបុណ្យ ។

អាស្រ័យហេតុនេះ បើខ្ញុំព្រះករុណា អាត្មាភាពសំដែងទៅហើយ ក្រែងបើលើសលោះខ្វះខាត លើសបទខ្វះបាឋ វោតវត្ត ព្យញ្ជនៈ អក្ខរ ឬសេចក្តីអធិប្បាយបរិយាយពន្យល់ន័យ ត្រង់កន្លែងណា ពុំគាប់អធ្យា ស្រ័យព្រះទ័យ ទឹកចិត្តនោះទេ សូមសន្តោសប្រោសប្រណីខន្តីអភ័យ ដល់ខ្ញុំព្រះករុណា អាត្មាភាព នឹងបានសំដែងទៅតាមសតិវោហារ ការ ចេះចាំតិចតួចស្តួចស្តើង មានការចេះចាំនោះក៏តិចភ្លេចនោះក៏ច្រើន សូមប្រគេនពរ និងជូនពរ ។

**នមោ**

**តស្ស ភគវតោ**

**អរហតោ សម្មាសម្ពុទ្ធស្ស ។**

សូមនមស្សការ ថ្វាយបង្គំព្រះសម្មាសម្ពុទ្ធ ដូចបទបាលីថា **យោ សន្និសិន្នោ វរពោធិមូលេ** ប៉ុណ្ណោះជាដើម បានសេចក្តីថា ព្រះសម្មា សម្ពុទ្ធអង្គឯណា ទ្រង់គង់ចំរើន នូវព្រះអានាបាណស្សតិកម្មដ្ឋាន លើ

គេនបល្ល័ង្កក្រោមម្លប់ពោធិព្រឹក្សដ៏ប្រសើរ បានផ្ចាញ់នូវមារាធិរាជ ព្រម ទាំងសេនាដ៏ច្រើន ហើយទ្រង់ត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ មាន ប្រាជ្ញារកទីបំផុតគ្មាន ព្រះអង្គប្រសើរជាងសត្វលោក ខ្ញុំព្រះករុណា សូម ក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធអង្គនោះដោយសេចក្តីគោរព។

សូមថ្វាយបង្គំចំពោះព្រះសទ្ធម្ម ដូចបទបាលីថា **អដ្ឋង្គិកោរិយប ថោ ជនានំ** ប៉ុណ្ណេះជាដើម បានសេចក្តីថា ព្រះសទ្ធម្មឯណា ជាធម៌ ប្រកបដោយអង្គ ៨ ប្រការ ជាគន្លងដំណើរ នៃព្រះអរិយបុគ្គលជាម្ចាស ជាផ្លូវដ៏ត្រង់ក្នុងកិរិយា ញ៉ាំងជនដែលប្រាថ្នានូវព្រះនិព្វាន ឱ្យចូលទៅ កាន់ព្រះនិព្វាន ព្រះធម៌នេះ ជាធម៌ធ្វើឱ្យត្រជាក់ រម្ងាប់បង់នូវភ្លើងទុក្ខ ភ្លើងកិលេស ជាធម៌ដ៏ឧត្តម ជាគុណញ៉ាំងសត្វ ឱ្យចេញចាកសង្សារទុក្ខ ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះសទ្ធម្មនោះដោយសេចក្តីគោរព។

សូមថ្វាយបង្គំចំពោះព្រះអរិយសង្ឃ ដូចបទបាលីថា **សង្ឃោ វិសុទ្ធោ វរទក្ខិណេយ្យោ** ប៉ុណ្ណេះជាដើម បានសេចក្តីថា ព្រះអរិយ សង្ឃឯណា ដ៏បរិសុទ្ធវិសេស ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ មាន ឥន្ទ្រិយរម្ងាប់ហើយមានមន្ទិល គឺរាគាទិក្កិលេសទាំងពួង បន្សាត់បង់ ហើយ ជាព្រះសង្ឃដល់ហើយ នូវកិរិយាស់ប្រេចដោយគុណទាំងឡាយដ៏ ច្រើន ជាព្រះសង្ឃមានអាសវធម៌មិនមាន គឺថាជាព្រះខីណាស្រព ខ្ញុំ ព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះអរិយសង្ឃនោះ ដោយសេចក្តី

គោរព ។

បទនមស្សការ សូមសង្ខេបបែបខ្លីតែប៉ុណ្ណេះ សព្វន្តរាយនិវារណគាថាក្តី ការធ្វើបទនមស្សការមកប៉ុណ្ណេះនេះ ដើម្បីការពាររារាំង នូវទុក្ខទោសគ្រោះថ្នាក់ ឧបស័គ្គ ភយន្តរាយផ្សេងៗ ដែលធ្លាប់មានមកដល់ខ្ញុំព្រះករុណា អាត្មាភាព និងពុទ្ធបរិស័ទទាំងឡាយ តាំងពីពេលមុនមកយូរយារណាស់មកហើយក្តី ឬចង្រៃឧបទ្រព កាឡកិណ្ណី អពមង្គល ណាមួយ បំរុងនឹងចូលមក រុករានទន្ទ្រានយាយីបៀតបៀន ក្នុងគ្រាឥឡូវនេះក្តី ក៏សូមឱ្យបាបគ្រោះទាំងនោះ បវៀសចៀសចេញឆ្ងាយចាកពីខន្ធសន្តានរបស់យើងទាំងឡាយ ។

**ឯតេន សច្ចវជ្ជេន ទុក្ខំ ហោតុ សព្វទា** ដោយសច្ចវាចាគឺវាចាពិត ដែលបានរៀបរាប់ មកប៉ុណ្ណេះនេះ សូមសិរីសួស្តីជ័យមង្គលសុខចំរើនគ្រប់ប្រការ កើតមានដល់ ព្រះករុណាគ្រប់ព្រះអង្គ និងពុទ្ធបរិស័ទទាំងឡាយឱ្យបានសព្វកាលតរៀងទៅ កុំបីមានឧបស័គ្គណាមួយមកបៀតបៀនបានឡើយ ។

**ឥតោ បរំ កឋិនំ អារព្ភស្សាមិ** ដទៃអំពីបទនមស្ការ និងអាយាចនគាថា នេះទៅ នឹងប្រារព្ធ សំដែងអធិប្បាយ វែកញែកចែកជូនរំគាយសេចក្តី ពន្យល់ន័យ នូវពាក្យថា "**កឋិន**" ។

ពាក្យថា "**កឋិន**" ស័ព្ទនេះ បើតាមអដ្ឋកថា លោកសំដៅយក

ព្រះពុទ្ធដីកា ដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែងបញ្ញត្តិទុកមកថា បានដល់ការប្រជុំប្រមូលរូបធម៌ និងនាមធម៌ ហៅថា កឋិន. លោកពន្យល់ថាមកពីស័ព្ទដើម គឺកថធាតុ ដែលប្រែថា ពោល ឬសំដែង ប្រព្រឹត្តទៅក្នុងអត្ថ ២ យ៉ាងគឺ:

១. កឋិន ប្រែថា "រស់នៅបានដោយរកម្រ" សមដូចបទវិគ្គហថា **កថេតិ កិច្ឆេន ជីវតីតិ កឋិនោ** សភាវៈឯណារស់នៅបានដោយកម្រ សភាវៈនោះ ហៅថា កឋិន ព្រោះលោកប្រៀបថា ដូចជាឈើស្ងួត ដែលបុគ្គលកាត់ចេញចាកដើម ហើយយកទៅបោះភ្ជាប់នឹងផែនដី រមែងដុះលូតលាស់ ឬរស់នៅបានដោយកម្រយ៉ាងណា ឯកិច្ចដែលនឹងកើតឡើង ឬតាំងឡើងជាកឋិនពេញទី គឺបានដោយកម្រពន់ពេកណាស់ ក៏យ៉ាងនោះដែរ ។

២. កឋិន ប្រែថា "ពោលសរសើរ" ព្រោះចីវរទាន ដែលយើងបានកសាង ជាកឋិននោះ ជាទានវិសេសជាងទានដទៃ១ ដែលព្រះអរិយៈទាំងឡាយ មានព្រះសម្ពុទ្ធជាប្រធាន តែងពោលសរសើរថា ជាទានវិសេសវិសាល អាចប្រមូល ឬសង្គ្រោះនូវអានិសង្ស ៥ យ៉ាង របស់ភិក្ខុក្រាលគ្រង មិនឱ្យទៅក្រង់ទីដទៃបាន សមដូចវិគ្គហថា: **បញ្ច អានិសំសេ អញ្ញត្ថ គន្តុំ អទត្វា កថតិ សង្គណ្ហាតីតិ > កឋិនំ** ប្រែថា ធម្មជាតិឯណា ក្រៀកទុក ឬសង្គ្រោះនូវអានិសង្សទាំង ៥ មិនឱ្យ

ទៅក្នុងទីបំផុតបាន ធម្មជាតិនោះឈ្មោះថា "កឋិន" កឋិននេះអាចឱ្យសំរេចផលដល់បុគ្គលទាំងពីរផ្នែក គឺទាយកអ្នកអោយ ក៏ត្រូវបានអានិសង្សច្រើន ត្រូវទទួលផលប្រយោជន៍ ក្នុងអនាគតដែលខ្លួនត្រូវបានមានការទទួលនូវសម្បត្តិក្នុងឋានទេវលោកជាដើម ចំណែកបដិគ្គាហកៈគឺភិក្ខុអ្នកទទួលក្រាលគ្រងកឋិន និងបុគ្គល ឬគណៈ ព្រមទាំងសង្ឃដែលបានអនុមោទនា ក៏សំរេចនូវអានិសង្សទាំង ៥ ប្រការពេញលេញគ្រប់គ្រាន់ដរាបដល់អស់រយៈកាលនៃកឋិនខេត្ត ។

## ឧប្បត្តិហេតុនៃកឋិន

ដើមហេតុដែលនាំឱ្យកើតកឋិនទាននេះ ដោយមានសេចក្តីដំណាលថាៈ សម័យមួយនោះ នៅក្នុងរវាងមជ្ឈិមពោធិកាល ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ដែលជាអារាមរបស់អនាថបណ្ឌិតសេដ្ឋី សាងថ្វាយទៀបក្រុងសាវត្ថី គ្រានោះ មានភិក្ខុ ៣០ អង្គឈ្មោះថាភទ្ទវគ្គិយត្ថេរក្នុងដែនបាវេយ្យ ជាអ្នកប្រព្រឹត្តធុតង្គនៅក្នុងព្រៃ។ល។ ក៏នាំគ្នាចេញពីទីនោះ មកកាន់ក្រុងសាវត្ថី ដើម្បីគាល់បំរើព្រះមានព្រះភាគ ទើបតែមកដល់ពាក់កណ្តាលផ្លូវជួនជាដល់ថ្ងៃចូលវស្សា នឹងស្រូតមកទៀតពុំទាន់ ក៏នាំគ្នាស្វែងរកសេនាសនៈនៅចាំវស្សា ទៀបក្រុងសាកេត នាពាក់កណ្តាលផ្លូវនោះទៅ ភិក្ខុទាំងនោះមានសេចក្តីអផ្សុកជាខ្លាំង ដោយគិតឃើញថាៈ

ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងទីនោះ ចម្ងាយ ៦ យោជន៍ទៀតសោះ មិនសមយើងទាំងឡាយ ស្អុនដំណើរមិនបានទៅគាល់បំរើព្រះអង្គ លុះដល់ថ្ងៃចេញវស្សា បវារណាស្រេចហើយ លោកក៏នាំគ្នាស្រុតចេញ អំពីទីនោះមកទៀត ទទួលរដូវនោះនៅមានភ្លៀងរលឹមជោកជាំនៅឡើយ តាមផ្លូវទៅមកពោរពាសដោយទឹកនឹងភក់រអិលប៉ិចប៉ាច់។ លុះដល់ក្រុងសាវត្ថីហើយ ចូលទៅកាន់វត្តជេតពន ដែលព្រះមានព្រះភាគទ្រង់គង់នៅ ក្រាបថ្វាយបង្គំព្រះមានព្រះភាគរួចស្រេចហើយ ក៏អង្គុយក្នុងទីដ៏សមគួរ លំដាប់នោះព្រះមានព្រះភាគ ទ្រង់មានបន្ទូលរាក់ទាក់ទៅកាន់ភិក្ខុទាំងនោះថា: ម្នាលភិក្ខុទាំងឡាយ! សរីរយន្តរបស់អ្នកទាំងឡាយ ល្មមអត់សង្កត់បានឬទេ ល្មមប្រព្រឹត្តទៅបានឬទេ! អ្នកទាំងឡាយមានសេចក្តីព្រមព្រៀងស្មោះស្មើ ឥតមានវិវាទទាស់ទែងគ្នាឬទេ ? អ្នកទាំងឡាយនៅចាំវស្សាសោត ស្រួលបួលមិនលំបាកដោយអាហារបិណ្ឌបាតឬទេ ? ភិក្ខុទាំងឡាយនោះ ក្រាបបង្គំទូលតាមដំណើរនោះរួចហើយ ក៏ក្រាបបង្គំទូលរំពីសេចក្តីលំបាករបស់ខ្លួន ដែលមានមកតាមផ្លូវ ដោយសព្វគ្រប់តាមដំណើរ ។

លំដាប់នោះព្រះមានព្រះភាគ ទ្រង់សំដែងធម្មីកថាប្រារព្ធអំពីសង្សារវដ្តមិនមានទីបផុត ប្រោសប្រទានភិក្ខុទាំងនោះ លុះចប់ធម៌ហើយ ភិក្ខុទាំងនោះក៏បានជាព្រះអរហន្តទាំងអស់អង្គ ហើយនាំគ្នា

ហោះតាមអាកាសទៅកាន់ទីលំនៅរបស់ខ្លួនរៀងទៅ ។

បន្ទាប់ពីនោះមក ព្រះមានព្រះភាគ ទ្រង់តម្រិះថា បើប្រសិនជាតថាគត បានតែងតាំងកឋិនត្ថារកិច្ច ទុកអំពីគ្រាមុន ម្ល៉េះសមភិក្ខុទាំងនុ៎ះ នឹងបានលះចីវរមួយទុកនៅទីកន្លែង ជាប់មកតែស្បង់ជីពរប៉ុណ្ណោះ មានអត្តភាពស្រាលមិនលំបាកយ៉ាងនេះសោះឡើយ។ ហើយកឋិនត្ថារកិច្ចនេះសោត ព្រះពុទ្ធទាំងឡាយរាល់ព្រះអង្គ ក៏តែងទ្រង់អនុញ្ញាតទុកដល់សាវកកុំដែលលះបង់ផង ព្រះមានព្រះភាគទ្រង់ព្រះតម្រិះដូច្នេះហើយ ទើបទ្រង់ត្រាស់ ហៅភិក្ខុទាំងឡាយមកអនុញ្ញាត កឋិនត្ថារកិច្ចនេះ ដោយព្រះពុទ្ធដីការថា:

**អនុជានាមិ ភិក្ខវេ វស្សំ វុដ្ឋានំ ភិក្ខូនំ កឋិនំ**

**អត្ថរិតុំ អត្ថត កឋិនានំ វោ ភិក្ខវេ បញ្ច កប្បិស្សន្តិ**

ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុទាំងឡាយ ដែលបាន នៅចាំវស្សារួចហើយ ទទួលក្រាលកឋិន ម្នាលភិក្ខុទាំងឡាយ កាលបើ ភិក្ខុទាំងឡាយ បានក្រាលកឋិនហើយ នឹងបានសំរេចអានិសង្ស ៥ ប្រការ ។

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់សំដែងថា អ្នកមានសទ្ធាជ្រះថ្លា សូម្បីបព្វជិត ឬគ្រហស្ថ ក៏អាចធ្វើកឋិន មានដូចតទៅនេះ :

១. ដោយមានគោលបំណង ដើម្បីទ្រទ្រង់នូវប្រពៃណីរបស់បុព្វ

បុរស ឱ្យមានសកម្មភាពរស់រវើកឡើងវិញ ព្រោះថាកឋិនទាននេះ បុព្វបុរសដ៏ជាទីគោរពស្នេហានៃយើង លោកធ្លាប់បានធ្វើ ហើយក្លាយមកជាទម្លាប់បង្កើតបានមកជាប្រពៃណីមានមកអស់កាលដ៏យូរលង់ហើយ។

ពិសេសដើម្បីលើកស្ទួយ នូវព្រះបរមពុទ្ធានុញ្ញាត ឱ្យថ្កុំថ្កើងរុងរឿង ដែលព្រះសម្មាសម្ពុទ្ធ ដ៏ជាទីសក្ការនៃយើង ទ្រង់បានអនុញ្ញាតចំពោះព្រះសង្ឃរវាងមជ្ឈិមពោធិកាល ដូចបានពោលមកហើយពីខាងដើម ។

២. ដោយមានគោលបំណង ដើម្បីអនុគ្រោះចំពោះព្រះសង្ឃដែលបានគោរពកិច្ច ចាំវស្សាមិនឱ្យដាច់ អស់រយៈកាល៣ខែ កុំឱ្យលំបាកក្នុងដំណើរ ដែលត្រូវស្វះស្វែងរកសំពត់ និងឧបករណ៍ផ្សេងៗ ទៀតមកធ្វើកឋិន ។

៣. ដោយមានគោលបំណង ដើម្បីលើកតម្កើង នូវវប្បធម៌ជាតិ និងលើកស្ទួយព្រះពុទ្ធសាសនា ឱ្យបានថ្កុំថ្កើងរុងរឿងរីកចំរើនអស់កាលដ៏យូរអង្វែង ។

៤. ដោយយល់ឃើញថា ជីវិតរបស់សព្វសត្វក្នុងលោកសន្និវាសនេះមិនទៀង ពុំដឹងជាស្លាប់ទៅវិញពេលណា ? ស្របនឹងអនិមិត្តកធម៌ត្រង់ប្រការទី ១ ចែងថា: "**ជីវិតអនិមិត្តកៈ**" ប្រែថា ជីវិតគឺការរស់នៅរបស់សព្វសត្វ ពុំមានបុគ្គលណាមួយកំណត់បានស្មានត្រូវឡើយ ។

ន័យនេះ ស៊ីសង្វាក់គ្នានឹងព្រះបន្ទូលរបស់ព្រះបរមពោធិសត្វនៃយើង ទ្រង់ព្រះនាមព្រះតេមិយកុមារ ដែលទ្រង់ថ្លែងទៅកាន់ព្រះមាតាបិតាថា: "សេចក្តីព្យាយាមក្នុងកុសលគេគួរធ្វើក្នុងថ្ងៃនេះឯង បុគ្គលណាអាចដឹងថា សេចក្តីស្លាប់នឹងមានមកក្នុងថ្ងៃស្អែក! បើការបណ្តោះបណ្តៃពីសេចក្តីស្លាប់ ដែលមានសេនាដ៏ច្រើន នោះមិនមានដល់យើងសោះ ។

មូលហេតុទាំង ៤ ប្រការនេះហើយ ដែលហាក់ដូចជារឿមួយមានឥទ្ធិពលដ៏ខ្លាំងក្លា រុញច្រាន ឱ្យពុទ្ធបរិស័ទបបួលគ្នាធ្វើបុណ្យកឋិនទាននេះឡើង ។

ម្យ៉ាងទៀត តាមជំនឿរបស់យើងជាពុទ្ធសាសនិកដែលបានយល់ដឹងថា កឋិនទាននេះ ជាទានមានផលានិសង្សច្រើនទូលំទូលាយល្អក្រកាល វិសេសវិសាល អនេក អនគ្ឃ មហគ្ឃ មហន្ត ពន់ប្រមាណជាង ទានទានាព្រោះថា:

១. កឋិនទាន គេអាចធ្វើបានតែក្នុងពុទ្ធកាល ឬសម័យដែលមានព្រះពុទ្ធសាសនា មានជីវិតគង់ទ្រង់នៅ ។

២. កឋិនទាន ជាកាលទាន គឺជាទានមានកំរិតក្របខ័ណ្ឌពេលវេលាត្រឹមត្រូវ ក្នុង១ឆ្នាំមានរយៈកាលធ្វើកឋិនបានតែ ១ខែ ហើយដែលមានតែ ២៩ថ្ងៃទៀត ដោយគិតពីថ្ងៃ ១រោច ខែអស្សុជដល់ថ្ងៃ ១៥កើត ខែកត្តិក ។

៣. កឋិនទាន ជាសង្ឃគតាមក្ខិណោទាន គឺបើនឹងធ្វើកឋិន លុះត្រាតែមានព្រះសង្ឃ ដែលមានកំណត់ចំនួន ៥ ព្រះអង្គយ៉ាងតិច ។

រីឯបុគ្គល លោកជាអ្នកក្រាលគ្រង ត្រូវជាអ្នកបានចូលបុរិមិកវស្សា គឺចូលវស្សានូវថ្ងៃ ១រោច ខែអាសាឍ ពុំមែនជាអ្នកចូលបច្ឆិមវស្សា គឺចូលវស្សានូវថ្ងៃ ១រោច ខែស្រាពណ៍ ពុំមែនជាអ្នកមិនចូលចាំវស្សា ហើយក៏ពុំមែនជាអ្នកដាច់វស្សា ។ល។

៤. កឋិនទាន ជាទានប្រកបដោយបញ្ញាដោយសង្ឃបុគ្គលទាំងបដិគ្គាហកៈ អ្នកទទួល ទាំងទាយក អ្នកឱ្យទាន ត្រូវជាអ្នកប្រកបដោយបញ្ញាយល់ដឹង ប្រែថា អ្នកមានបច្ចេកទេសខាងព្រះវិន័យ ឬថាជាទានខាងព្រះវិន័យ ។

៥. កឋិនទាន ជាទានមានផលានិសង្សប្លែកជាងទានឯទៀតៗ ដែលអាចអំណោយផលដល់បដិគ្គាហកៈ គឺបុគ្គលគណៈ ឬព្រះសង្ឃ ជាអ្នកក្រាលគ្រង និងអនុមោទនា ដល់ទាយក ទាយិកា ជាម្ចាស់ទានផង ។

តាមអត្ថន័យនេះ ឃើញថាពុទ្ធបរិស័ទយើងគ្រប់រូបទាំងអស់ដែលបានរួបរួមគ្នាធ្វើកឋិនទាននេះប្រាកដជាត្រូវបានទទួលផលានិសង្សជាអសង្ខេយ្យ ពុំអាចឧបមេយ្យបានតាមគួរដល់កុសលចេតនាជាមិនខាន

តោ សាធុ ទោ ហៃសាធុសប្បុរសទាំងឡាយ! ដើម្បីឱ្យកឋិនទាន មានផលច្រើន ដូចពោលមកហើយប្រការដែលសំខាន់ ក្នុងពេល

វេរ អង្គព្រះកឋិនទាន ម្ចាស់បុណ្យគ្រប់រូប គប្បីផ្តោតអារម្មណ៍ បាញ បោះស្មោះត្រង់ វេរអង្គព្រះកឋិនទានប្រគេនចំពោះព្រះសង្ឃ កុំងាកវេរ ទៅរកបុគ្គលឱ្យសោះ ។

**សំពត់ដែលគួរក្រាលកឋិនមាន ៥ យ៉ាងគឺ:**

១. សំពត់ថ្មី

២. សំពត់ធៀបថ្មី

៣. សំពត់ចាស់

៤. សំពត់បង្សុកូល

៥. សំពត់ធ្លាក់តាមរានផ្សារ ។

**សំពត់ដែលមិនគួរក្រាលកឋិនមាន ៥ យ៉ាងគឺ:**

១. សំពត់ដែលមិនមែនជាសិទ្ធិ

២. សំពត់ដែលបានមកដោយអាការធ្វើនិមិត្ត

៣. សំពត់ដែលបានមកដោយនិយាយបញ្ឆិតបញ្ចៀង

៤. សំពត់ត្រូវនិស្សគ្គិយ

៥. សំពត់ទុកឱ្យកន្លងរាត្រី ។

ភិក្ខុប្រកបដោយអង្គ ៨ ប្រការគួរឱ្យក្រាលកឋិន

**អង្គ ៨ ប្រការនោះគឺ**

១. ចេះបុព្វករណ៍

២. ចេះដកត្រៃចីវរ

៣. ចេះអធិដ្ឋានត្រៃចីវរ

៤. ចេះក្រាលកឋិន

៥. ចេះមាតិកា

៦. ចេះពលិពោធ ដោយហេតុនៅមិនដោះកឋិន

៧. ដឹងនូវហេតុដោះកឋិន

៨. ស្គាល់អានិសង្សកឋិន ។

**បុព្វករណ៍ហេតុខាងដើមនៃកឋិនមាន ៧ យ៉ាងគឺ:**

១. បោកគក់សំពត់

២. វាស់សំពត់

៣. កាត់សំពត់

៤. ដុលភ្ជាប់សំពត់

៥. ដេរជាចីវរ

៦. ជ្រលក់ចីវរដែលដេរហើយ

៧. ធ្វើវិកប្ប ពិន្ទុ ។

**ដកត្រៃចីវរថាដូច្នេះ**

សំពត់សង្ឃាដីថា: **ឥមំ សង្ឃាដឹ បច្ចុទ្ធរាមិ** [១]

សំពត់ចីវរថា: **ឥមំ ឧត្តរាសង្គំ បច្ចុទ្ធរាមិ**

សំពត់ស្បង់ថា: ឥមំ អន្តរវាសកំ បច្ចុទ្ធរាមិ ។

## អធិដ្ឋានត្រៃចីវរថាដូច្នេះ

សំពត់សង្ឃាដីថា: ឥមំ សង្ឃាដឹ អធិដ្ឋាមិ (២)

សំពត់ចីវរថា: ឥមំ ឧត្តរាសង្គំ អធិដ្ឋាមិ

សំពត់ស្បង់ថា: ឥមំ អន្តរវាសកំ អធិដ្ឋាមិ ។

## ពាក្យក្រាលកឋិនថាដូច្នេះ

សំពត់សង្ឃាដីថា: ឥមាយ សង្ឃាដិយា កឋិនំ អត្ថរាមិ (៣)

សំពត់ចីវរថា: ឥមិនា ឧត្តរាសង្គេន កឋិនំ អត្ថរាមិ

សំពត់ស្បង់ថា: ឥមិនា អន្តរវាសកេន កឋិនំ អត្ថរាមិ ។

## មាតិកា ៨ នោះគឺ:

១. កំណត់ដោយការចេញទៅៗ ដោយគិតថានឹងត្រឡប់

២. កំណត់ដោយធ្វើចីវរស្រេចហើយ

៣. កំណត់ដោយសន្និដ្ឋានថានឹងមិនធ្វើ

៤. កំណត់ដោយការខូច ឬបាត់

៥. កំណត់ដោយអស់សង្ឃឹម

៦. កំណត់ដោយបានឮដឹង

---

(១) ប្រែថា អាត្មាអញដកនូវសំពត់សង្ឃាដិកានេះ ស្បង់ និងចីវរមានន័យដូចគ្នា ។

(២) អាត្មាអញតាំងទុកនូវសំពត់សង្ឃាដិកានេះ ស្បង់ និងចីវរមានន័យដូចគ្នា ។

៧. កំណត់ដោយរបស់ខេត្ត

៨. កំណត់ដោះព្រមជាមួយនឹងភិក្ខុទាំងឡាយ ។

**អនុមោទនាកឋិន**

**អត្ថ តំ { អាវុសោ / ភន្តេ } សង្ឃស្ស កឋិនំ ធម្មិកោ កឋិនត្ថារោ**

**មោ អនុមោ { ទថ / ទាមិ }**

ប្រែថា ម្នាលភិក្ខុទាំងឡាយ កឋិនរបស់សង្ឃក្រាលហើយការក្រាលកឋិន ជាធម៌ត្រឹមត្រូវ តាមរបៀបហើយចូរភិក្ខុទាំងឡាយ អនុមោទនាចុះ ។

**ពលិពោធ ២ យ៉ាងគឺ:**

១. **អាវាសពលិពោធ** វល់ក្នុងអាវាស

២. **ចីវរពលិពោធ** វល់ក្នុងចីវរ ។

ពាក្យថា **ចីវរ** ប្រែថា សំពត់ដែលភិក្ខុគប្បីសន្សំ។ មកអំពីសព្ទដើមគឺ **ចិធាតុ** និង **ឦវរ** បច្ច័យ (ចិ+ឦវរ) ។

**ចីវរនេះមាន ២ យ៉ាងគឺ:**

១. **បង្សុកូលចីវរ** ចីវរដែលភិក្ខុបានមករំពីសំពត់បង្សុកូល ។

២. **គហបតីចីវរ** ចីវរដែលទាយក ទាយិកា គេប្រគេន ។

ពុទ្ធបរិស័ទទាំងឡាយ! **ចីវរ សង្ឃាដី ស្បង់** ត្រៃបីនេះ ត្រូវកាត់ ផាច់ជាកំណាត់ៗ ហើយដេរភ្ជាប់គ្នាវិញយ៉ាងនេះទើបសមគួរដល់ភេទសមណៈ ព្រោះមានបាលីដែលទ្រង់អនុញ្ញាតថា: **អនុជានាមិ ភិក្ខវេ ឆិន្នកំ សង្ឃាដី ឆិន្នកំ ឧត្តរាសង្គំ ឆិន្នកំ អន្តរវាសកំ** ។

ប្រែថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឱ្យអ្នកទាំងឡាយប្រើប្រាស់សង្ឃាដីដែលកាត់ផាច់, ចីវរដែលកាត់ផាច់, ស្បង់ដែលកាត់ផាច់ ។

បើភិក្ខុប្រើប្រាស់នូវត្រៃចីវរ មិនបានកាត់ផាច់ណាមួយ ត្រូវអាបត្តិទុក្កដ ។

ចីវរមាន ៤ បែបគឺ:

| | |
|---|---|
| ១. បញ្ចខណ្ឌ | ខណ្ឌ ៥ មានកន្សៀង ១០ |
| ២. សត្តខណ្ឌ | ខណ្ឌ ៧ មានកន្សៀង ១៤ |
| ៣. នវខណ្ឌ | ខណ្ឌ ៩ មានកន្សៀង ១៨ |
| ៤. ឯកាទសខន្ធ | ខណ្ឌ ១១ មានកន្សៀង ២២ ។ |

អង្គនៃតិចីវរមាន ១០ យ៉ាងគឺ:

១. កុសិ — ចំរៀកវែង
២. អឌ្ឍកុសិ — កន្លះចំរៀកវែង គឺចំរៀកខ្លី
៣. មណ្ឌល — កន្ទៀងធំ
៤. អឌ្ឍមណ្ឌល — កន្លះកន្ទៀងធំ គឺកន្ទៀងតូច
៥. វិវដ្ដ — ផ្ទាំងបើកចំកណ្ដាល
៦. អនុវិវដ្ដ — បើកបន្ទាប់ពីផ្ទាំងរវម
៧. ពាហន្ត — ជើមដៃ
៨. ជង្ឃេយ្យកៈ — ព្រង់ស្មង
៩. គីវេយ្យកៈ — ព្រង់ក
១០. អនុវាត — ផ្ទាំងតូចជុំវិញ ។

អដ្ឋបរិក្ខារ

សម្ភារៈ ឬវត្ថុ សំរាប់ព្រះសង្ឃប្រើប្រាស់ ៨ យ៉ាងគឺ:

១. អន្តរវាសកោ — ស្បង់
២. ឧត្តរាសង្គោ — ចីពរ
៣. សង្ឃាដិ — សង្ឃាដិ
៤. បត្តោ — បាត្រ
៥. សត្ថកេសរោ — កាំបិតកោ

៦. សុចិឃរៈ បំពង់ម្ជុល

៧. អាយពន្ធនំ វត្ថពន្ធចង្កេះ

៨. ធម្មការកំ ធម្មក្រក ( តំរងទឹក ) ។

បុច្ឆា. ចីវរទាន មានអានិសង្ស ដូចម្តេចខ្លះ ?

វិសជ្ជនា. មានអានិសង្សដូច្នេះ បើជាបុរសយល់បច្ឆិមជាតិ ត្រូវបានសម្រេចជា ឯហិភិក្ខុ ព្រៃចីវរកើតឯង បើជាស្ត្រីនឹងបានសម្រេចគ្រឿងលតាមហាប្រាសាទន៍ បើមិនទាន់បានយល់ព្រះនិព្វានទេ ទៅកើតក្នុងភពណាៗ មានពណ៌សម្បុរល្អនឹងសម្រេចបាននូវសំពត់ទិព្វ ដូចមាននិទានតទៅនេះ :

សេចក្តីថា កាលដ៏កន្លងទៅហើយ មានកុដុម្ពីម្នាក់ នៅក្នុងក្រុងពារាណសី ចូលទៅក្នុងព្រៃ បានឃើញព្រះបច្ចេកពុទ្ធកំពុងធ្វើចីវរមិនទាន់ហើយខ្វះអនុវាត បានប្រគេនសំពត់បង់កររបស់ខ្លួនទៅ ព្រះបច្ចេកពុទ្ធ (លុះច្យុតចាកអត្តភាព )នោះ បានទៅកើតក្នុងស្ថានតាវត្តិង្ស ដោយកុសលកម្ម ដែលខ្លួនបានប្រគេនសំពត់ដល់ព្រះបច្ចេកពុទ្ធនោះ។ លុះច្យុតចាកស្ថានតាវត្តិង្សមក បានទៅកើតក្នុងត្រកូលអាមាត្យ មានលំនៅចម្ងាយពីក្រុងពារាណសី ១យោជន៍ ។

លុះមានវ័យចំរើនឡើងហើយ និយាយនឹងម្តាយថាបពិត្រអ្នកម្តាយ សូមអោយសំពត់សាដកមកខ្ញុំ ១ នឹងទៅលេងនក្ខត្តឫក្ស ជាមួយ

នឹងគេ ម្ដាយក៏ឱ្យសំពត់ដែលបោកទឹករួចហើយមក កូននោះប្រកែកថា សំពត់នេះគ្រាស់ណាស់ ម្ដាយក៏បានប្ដូរឱ្យសំពត់ផងទៀតវិញ ក៏នៅតែប្រកែក មិនព្រមយក។ ម្ដាយប្រាប់ថា គ្មានសំពត់សាច់ល្អិតជាងនេះទេកូន! កូន នោះតបថា បើគ្មានខ្ញុំនឹងទៅស្វែងរកគ្រាតែបាន ម្ដាយក៏ឆ្លើយរាងយក ប្រមាណ ព្រហ្មវិហាររបស់ខ្លួនថា: អើកូន! អញប្រាថ្នាឱ្យឯង សោយ រាជ្យក្នុងនគរពារាណសីថ្ងៃនេះផង មិនត្រឹមតែចង់ ឱ្យឯងបានសំពត់ សាច់ល្អប៉ុណ្ណោះទេ! កុមារនោះបានទទួល មធុរវាចា មាតាថា សាធុៗ ហើយបង្គំលាត្រាច់ទៅកាន់ក្រុងពារាណសី ។

ដោយគំនរបុណ្យផាស់ពៀន កុមារក៏ចូរទៅក្នុងឧទ្យាន ហើយ ដេកទទូរក្បាល លើផែនថ្មមង្គល ជួនជាថ្ងៃនោះជាថ្ងៃគំរប់ ៧ ដែល ស្ដេចក្នុងក្រុងពារាណសីទទួលទិវង្គតទៅ ពួកឥស្សរជន មានអាមាត្យជា ដើម បានធ្វើសរីរកិច្ចព្រះរាជារួចហើយ ប្រឹក្សាគ្នាថា ព្រះរាជាមានតែ ព្រះរាជធីតា ១ ព្រះអង្គ ឥតមានព្រះរាជបុត្រទេ តពីនេះទៅ មិនមាន ស្ដេចនឹងសោយរាជ្យជាបំណរវង្សតទៅទៀតទេ រាជសម្បត្តិមុខជានឹង វិនាសសាបសូន្យពុំខានឡើយ។ ហើយក៏ផ្សងបុស្សរថ ដែលទឹមដោយ សេះសិន្ធវៈ ៤ ដាក់គ្រឿងបញ្ចកកុធភ័ណ្ឌលើរថ១ ក៏ចេញទៅតាមទ្វារ ខាងកើតចូលទៅកាន់ឧទ្យានប្រទក្សិណកុមារហើយ ធ្វើអាការហាក់ដូច ជាលើកឡើងដាក់លើរថ. បុរោហិត បើកជាយសំពត់ពណ្ណប់ក្រឡេក

មើលឃើញផ្ទៃបាទជើងកុមារនោះ ក៏ប្រកាសប្រាប់គ្នាថា បុរសនេះគួរសោយរាជ្យហើយ បង្គាប់ឱ្យប្រគុំតូរ្យតន្ត្រី ៣ បទ ខណៈនោះកុមារបើកមុខឡើង ហើយសួរថា អ្នករាល់គ្នាធ្វើអ្វីហ្នឹង ? ពួកឥស្សរជនទាំងនោះក្រាបទូលថា បពិត្រព្រះសម្មតិទេព ព្រះអង្គត្រូវទទួលគ្រងរាជសម្បត្តិក្នុងក្រុងពារាណសីនេះ ហើយក៏ក្រាបទូលអំពីការ ផ្សងរកស្ដេចតាមដំណើរសេចក្ដីតាំងអំពីដើមរហូតមក ។

កុមារក៏ព្រមទទួល ទើបរាជបុរសទាំងនោះតាក់តែងមណ្ឌលអភិសេក ហើយបង្ហោនសំពត់មានដម្លៃ ១ ពាន់ កហាបណៈថ្វាយក្នុងខណៈនោះភ្លាម ព្រះរាជាអង្គនោះមានព្រះបន្ទូលថា សំពត់នេះក្រាស់ពេក អ្នករាល់គ្នាចូរយកកណ្ឌីមាសមកឱ្យយើង ទើបនឹងបានសំពត់ល្អ រួចក្រោកឡើង កាន់ទឹកជ្រួចទៅទិសទាំង ៤ ខណៈនោះស្រាប់តែដើមកល្បព្រឹក្សប្រាំបីៗ ដើម ទំលាយផែនដីដុះឡើងក្នុងទិសខាងកើត, ខាងត្បូង, ខាងលិច, ខាងជើង ។

ព្រះរាជាទ្រង់យកសំពត់ទិព្វនោះមកស្លៀក ១ ដណ្ដប់ ១ ហើយទ្រង់បង្គាប់ហាមមិនឱ្យពួកស្ត្រីក្នុងដែនធន្នរាជ ការសូត្រត្បាញសំពត់តទៅទៀត ហើយទ្រង់ប្រថាប់លើកដំរីយាងចូលកាន់នគរ ឡើងកាន់ប្រាសាទសោយនូវមហាសម្បត្តិរួចហើយធ្វើដែនរបស់ព្រះអង្គ ទាំងមូលឱ្យដូចឧត្តរកុរុទ្វីប ទ្រង់ព្រះរាជទានសំពត់ទិព្វ ដល់ពួកមនុស្សដែលមក

ដល់ ក្រោយមកទ្រង់បព្វជ្ជា ជាមួយនាងទៅនៅក្នុងឧទ្យាន ញ៉ាំងឈានឱ្យកើតឡើងហើយ ធ្វើមិនឱ្យសាបសូន្យទៅវិញ ( លុះច្យុតចាករវត្តភាពនោះ ) បានទៅកើតក្នុងព្រហ្មលោក។ ព្រះបាទរាជឧទ្ធរាជនោះគឺ ព្រះមហាកស្សបត្ថេរ ក្នុងកាលឥឡូវនេះ ព្រះនាងទេវី បានមកជានាងភទ្ទកាបិលានីនេះឯង ។

ពុទ្ធបរិស័ទទាំងឡាយ! កឋិនទាន ជាចីវរទាន ដូចចីវរទានទាំងពួងដែរ តែមានឈ្មោះវិសេសតាមកាលបរិច្ឆេទ ដែលធ្វើហៅថា កាលទាន ជាទានមានផលច្រើនជាងចីវរទានទាំងពួង ព្រោះប្លែកពីចីវរទានឯទៀត ដោយលក្ខណាការ ៥ យ៉ាងគឺ:

១. ប្លែកដោយកាល ព្រោះមានពុទ្ធានុញ្ញាតថា កឋិនកាល មានតែ ២៩ថ្ងៃ គឺខែអស្សុជ ១៤ថ្ងៃ ពីត្រឹម ១រោច ដល់ ១៤រោច (ខែផាត់ ) ខែកត្តិក ១៥ថ្ងៃ ពីត្រឹម ១កើត ដល់ ១៥កើត (ពេញបូណ៌មី ) ។

រយៈកាលនេះ ពាក្យសាមញ្ញ ហៅថា រដូវកឋិន ក្នុងរដូវនេះ ទាយកចង់ធ្វើថ្ងៃណាមួយក៏បាន ក្រៅពីថ្ងៃទាំង ២៩ នេះពុំបាន ហើយវត្ត ១ ធ្វើបានតែម្តង ក្នុងរដូវ ១ ទាំងភិក្ខុដែលបានទទួលកឋិនក្នុងរដូវនោះម្តងហើយទទួលម្តងទៀតពុំបាន ។

២. ប្លែកដោយវត្ថុ គឺសំពត់ដែលជារវត្ថុកឋិននោះបានតែស្បង់ ឬចីពរ ឬក៏សង្ឃាដី ដែលគេធ្វើត្រឹមត្រូវតាមពុទ្ធប្បញ្ញត្តិ សំពត់ក្រៅពីនេះ

ពុំបាន ហើយសំពត់ទាំង ៣ មុខទៀតសោត នឹងយកទាំងរស់ជាអង្គកឋិន ១ ក៏ពុំបាន បានតែ ១ នោះបីទាយក យកមកវេរចីវរ ១ត្រៃ គឺចីពរ ១ ស្បង់ ១ សង្ឃាដី ១ ជាសំពត់កឋិនមកវេរប្រគេនក៏ភិក្ខុអ្នកក្រាលគ្រង លោករើសយកតែវត្ថុណាមួយធ្វើជាអង្គកឋិន គឺលោកចង់យកស្បង់ក៏បាន ចីពរក៏បាន សង្ឃាដីក៏បាន ស្រេចលើព្រះទ័យលោក ឲ្យតែវត្ថុនោះត្រឹមត្រូវតាមវិនយបញ្ញត្តិ តែតាមធម្មតា លោកអ្នកក្រាលគ្រងច្រើនយកតែសង្ឃាដីជាអង្គកឋិន ដោយលោកយល់ថា បណ្ដាចីវរ ១ត្រៃ សង្ឃាដីជាចីវរធំជាងគេ ។

៣. ប្លែកដោយអំពើ គឺបុគ្គលអ្នកធ្វើ គប្បីធ្វើឲ្យត្រូវតាមរបៀបតាមវិនយបញ្ញត្តិ ហើយសង្ឃក៏គប្បីក្រាលគ្រង និងអនុមោទនា ឲ្យត្រឹមត្រូវ តាមវិនយបញ្ញត្តិដែរ ទើបកើតជាកឋិនពេញលក្ខណៈបាន ។

៤. ប្លែកដោយបដិគ្គាហកៈ គឺអ្នកទទួលសំពត់កឋិនបានតែភិក្ខុ ក្រៅពីភិក្ខុពុំបាន ហើយភិក្ខុនោះទៀត លុះតែបាននៅចាំវស្សា គ្រប់ ៣ ខែក្នុងវត្តណាមួយ ទើបទទួលក្រាលគ្រង និងអនុមោទនាកឋិនក្នុងវត្តនោះបាន ភិក្ខុដែលមិនបាននៅចាំវស្សា ឬបាននៅចាំវស្សាដែរ តែឲ្យដាច់ក៏ទទួលពុំបាន ។

៥. ប្លែកដោយអានិសង្ស គឺទាយកអ្នកធ្វើក៏បានអានិសង្សច្រើន ភិក្ខុសង្ឃអ្នកទទួលក្រាលគ្រង និងអនុមោទនាក៏បានអានិសង្ស ៥ យ៉ាង

ក្នុងរវាង ៥ ខែ ដូចមានក្នុងវិន័យបិដកភាគ ៨ ព្រះកឋិនក្ខន្ធកៈថាៈ

អានិសង្សកឋិន ៥ យ៉ាង

១. **អនាមន្តចារោ** ត្រាច់ទៅកាន់ទីដទៃ ដោយមិនបាច់លាភិក្ខុផងគ្នាបាន មិនមានទោស ក្នុងសិក្ខាបទទី ៦ នៃអចេលកវគ្គ បាចិត្តិយកណ្ឌ ។

២. **អសមាទានចារោ** ត្រាច់ទៅកាន់ទីណា ដោយមិនបាច់យកត្រៃចីវរគ្រប់ប្រដាប់ ជាប់ទៅជាមួយផងបាន ។

៣. **គណភោជនំ** ឆាន់គណភោជនបាន ។

៤. **យាវទត្ថចីវរំ** ទុកដាក់អតិរេកចីវរបានតាមត្រូវការ ។

៥. **យោ ច តត្ថ ចីវរុប្បាទោ សោ នេសំ ភវិស្សតិ** ចីវរណា ដែលកើតឡើង ក្នុងអាវាសនោះ ចីវរនោះនឹងមាន ដល់ភិក្ខុទាំងនោះ ។

ដោយកឋិនទានជាទានទាំឱ្យភិក្ខុសង្ឃ អ្នកទទួលក្រាលគ្រង និងអនុមោទនា បានអានិសង្ស ៥ យ៉ាង ដូចបានសម្តែងមកហើយ បានជាទាយកអ្នកធ្វើកឋិន ត្រូវបានផលានិសង្សច្រើនជាអនេកត្រារាប់ពុំបាន ព្រោះជាចីវរទានពិសេស ប្លែកពីចីវរទាននានា ដូចសម្តែងមកហើយផងជាចីវរទានឱ្យបានផលានិសង្ស ៥ យ៉ាង ដ៏ប្រកបដោយសេចក្តីសុខស្រួលដល់ព្រះភិក្ខុសង្ឃ អ្នកទទួលទានផង សមដូចព្រះពុទ្ធដីកាថាៈ

**សុខស្ស ទាតា មេធាវី សុខំ សោ អធិគច្ឆតិ** ជនអ្នកមានប្រាជ្ញា ( ណាមួយ ) បានឱ្យនូវសេចក្ដីសុខស្រួល ( ដល់អ្នកដទៃ ) ជននោះឯង រមែងបានជួបប្រទះនូវសេចក្ដីសុខ ( ជាពិតប្រាកដពុំខានឡើយ ) ។

បញ្ជាក់សេចក្ដីថា ជនណាមួយ មានបសាទសទ្ធា សេចក្ដីជ្រះថ្លា បានប្រារព្ធធ្វើកឋិនទាន ដែលនាំឱ្យព្រះភិក្ខុសង្ឃ បានទទួលនូវអានិសង្ស ៥ យ៉ាង ក្នុងរវាង ៥ ខែនោះ បានឈ្មោះថា ជាអ្នកឱ្យសេចក្ដីសុខស្រួលដល់អ្នកដទៃ ក្នុងបច្ចុប្បន្នជាតិនេះ ជននោះឯងតែងតែបានសុខក្នុងមនុស្សលោក និងទេវលោក ទៅក្នុងអនាគតជាតិ ហើយដោយអំណាចផលានិសង្ស នៃកឋិនទាននោះ ក្នុងកាលជាអនាគត ជននោះនឹងបានជាឯហិភិក្ខុ ឬឯហិភិក្ខុនី ដែលមានត្រៃចីវរកើតឯងដោយឫទ្ធិនៅពេលបព្វជ្ជា ជាបព្វជិតក្នុងសាសនាព្រះពុទ្ធ អង្គណាមួយ ហើយបានសម្រេចមគ្គផលនិព្វាន ក្នុងពេលបព្វជ្ជានោះ ដោយពិតប្រាកដពុំខានឡើយ ។

មួយកន្លែងទៀតព្រះអង្គទ្រង់សំដែងថា:

**យេ ជនា សុខមិច្ឆន្តា ឧត្វាន កឋិនចីវរំ តេបិ ឧត្វា បមុញ្ចន្តិ អត្វា ទេវេសុ មនុស្សេសុ នរកាទីនំ ន ជាយន្តិ កឋិនំ ទានស្សិទំ ផលំ ន ទេវលោកេ ចិរំ ភុត្វា ទិព្វសម្បត្តិ**

តតោ ចវិត្វា មនុស្សលោកេ រាជា ហោន្តិ មហព្វលា សត្តរតនំ សម្បន្នា ចតុទីបេសុ ឥស្សរា តេ ជនា សំសរន្តាបិ អបាយេ ន គមិស្សន្តិ ទ្វេ កុលេ ឧបបជ្ជន្តិ ខត្តិយេ ចាបិ ព្រាហ្មណេ ហីនេ កុលេ ន ជាយន្តិ កឋិនទានស្សិទំ ផលំ ។

ប្រែជាខេមរភាសាថា: ជនទាំងឡាយឯណាប្រាថ្នានូវសេចក្តីសុខ ហោយនូវចីវរដើម្បីកឋិនទាន ជនទាំងឡាយនោះឯង រមែងរួចចាកទុក្ខក្នុងទេវតា និងមនុស្សទាំងឡាយ និងមិនកើតក្នុងអបាយទាំងឡាយមាននរកជាដើម នេះជាផលរបស់កឋិនទាន ជនទាំងឡាយនោះនឹងបានសោយនូវសម្បត្តិដ៏ជាទិព្វ ក្នុងទេវលោកទាំង ៦ ជាន់អស់កាលដ៏យូរអង្វែង លុះច្យុតអំពីទេវលោកនោះមក និងបានជាស្តេចក្នុងមនុស្សលោកនេះ ជាស្តេចមានកម្លាំងជាច្រើន បរិបូណ៌ដោយរតនៈទាំង ៧ ប្រការ និង បានជាធំក្នុងទ្វីបទាំង៤ កាលអបាយទាំងឡាយ រមែងកើតក្នុងត្រកូលទាំងពីរគឺ ខត្តិយត្រកូល ១. ព្រាហ្មណត្រកូល ១. មិនកើតក្នុងត្រកូលថោកទាបឡើយ នេះជាផលរបស់កឋិនទាន ដែលជនទាំងឡាយបានកសាងហើយ ។

កន្លែងខ្លះទៀត ព្រះសម្មាសម្ពុទ្ធជាបរមគ្រូនៃយើងទ្រង់ត្រាស់សំដែងថា:

## បុណ្យមានអានិសង្ស ៥ យ៉ាង

១. **អភិក្កន្តវណ្ណា ទិសាយោ** មានប្រាជ្ញាភ្លៀវឆ្លាមុះមុត ។

២. **សុវណ្ណតា** មានពណ៌សម្បុរល្អ ។

៣. **សុរូបតា** មានរូបល្អ។

៤. **សុសណ្ឋានតា** មានទ្រង់ទ្រាយល្អ ។

៥. **ចក្កវត្តិ រាជា ហោតិ** និងបានទៅជាស្តេចចក្រពត្តិក្នុងជាតិណាមួយពុំខានឡើយ ។

**ភោ សាធវោ** ហៃសាធុសប្បុរសទាំងឡាយ!

ក្នុងពុទ្ធសម័យ មានស្ត្រីល្អ ដែលកម្រមានក្នុងលោក ឬស្ត្រីដែលបរិបូណ៌ដោយបុញ្ញាភិនីហារៈ

## រឿងនាងវិសាខា

ចាកគម្ពីរ ធម្មបទ ខុទ្ទកនិកាយ

កាលព្រះសម្ពុទ្ធ ទ្រង់គង់នៅក្នុងវត្តបុព្វារាម នាក្រុងសាវត្ថី ទ្រង់ប្រារព្ធនូវមហាឧបាសិកាឈ្មោះវិសាខា បានសំដែងធម្មទេសនា មានបទថា: **យថាបិ បុប្ផរាសិម្ហា** ដូច្នេះជាដើម ។

សេចក្តីថា នាងវិសាខា ជាធីតារបស់ធនញ្ជយសេដ្ឋីមាតាឈ្មោះសុមនាទេវី ពីតារបស់នាងឈ្មោះ មេណ្ឌកៈ ជីដូនឈ្មោះ ចន្ទបទុមា ។ នាងវិសាខា ជាស្ត្រីមានឧបនិស្ស័យខ្ពស់ បានសម្រេចសោតាបត្តិផលតាំងពី អាយុ ៧ ឆ្នាំ ជាមួយនឹងទារិកា ៥០០ នាក់ ជាបរិវាររបស់នាង

នាងជាស្ត្រីប្រកបដោយបញ្ចពិធកល្យាណីមានលំអ ៥ យ៉ាងគឺៈ

១. កេសកល្យាណ លំអសក់

២. មំសកល្យាណ លំអសាច់

៣. អដ្ឋិកល្យាណ លំអឆ្អឹង

៤. ឆវិកល្យាណ លំអសម្បុរផ្ទៃ

៥. វយកល្យាណ លំអវ័យ ។

អធិប្បាយ

១. កេសកល្យាណ លំអសក់ សក់នៃស្ត្រីមានលំអមានសរសៃល្អិត មានពណ៌ដូចជាស្លាបកំភេម កាលរំសាយចុះទៅមានចុងងឡើងលើ ដូចសណ្ឋានកន្ទុយក្ងោកពង់ មិនចេះស្កូវឡើយ សូម្បីមានអាយុ១០០ឆ្នាំហើយ ក៏នៅតែមានពណ៌រលង់រលើបល្អដូចកាលនៅពីក្មេង។ យ៉ាងនេះហៅថា លំអសក់ ។

២. មំសកល្យាណ លំអសាច់ សំដៅយកសាច់បបូរមាត់ ស្ត្រីមានលំអ សាច់បបូរមាត់ឡើងពណ៌ក្រហមរលោង ដូចផ្លែចាសទុំ ឬផ្លែទន្ទាប់ទុំ ជាសាច់ស្អាតឥតមន្ទិលសៅហ្មង ទោះបីមានអាយុមួយរយឆ្នាំហើយ ក៏នៅតែក្រហមរលោងស្រស់ដូចដើមយ៉ាងនេះហៅថាលំអសាច់

៣. អដ្ឋិកល្យាណ លំអឆ្អឹង សំដៅយកឆ្អឹងធ្មេញ ស្ត្រីប្រកបដោយលំអ មានធ្មេញជិតស្និទ្ធរាបស្មើ មិនចំពើសមានពណ៌សរលោង

ដូចជាត្បូងពេជ្រ ដែលជាងច្នៃយ៉ាងស្អាត ហើយដាក់តម្រៀបគ្នា ឬដូចជាស័ង្ខ ដែលបុគ្គលច្នៃយ៉ាងល្អ បើហានិយាយឡើងកាលណា មានពន្លឺទឹកជមព្រាតៗ សូម្បីមានអាយុមួយរយឆ្នាំហើយ ក៏ធ្មេញនៅតែល្អជិតស្និទ្ធ ដូចកាលអាយុ ១៦ ឆ្នាំ។ យ៉ាងនេះហៅថាលំអឆ្អឹង ។

៤. **ឆវិកល្យាណ** លំអសម្បុរថ្ងៃ បានដល់លំអពណ៌ស្បែកស្ត្រីប្រកបដោយលំអ មានពណ៌ពីរយ៉ាងគឺៈ ស ១ ខ្មៅ ១។ ស មានពណ៌ដូចផ្កា កណ្ណិកា រលីងរលោងស្អាតឥតមានអាចម៍រុយ ឬសម្លាកមន្ទិលសៅហ្មងឡើយ សូម្បីតែសម្លាកកមរមាស់មួយក៏គ្មាន លំអខាងពណ៌ខ្មៅ មានពណ៌ខៀវស្រស់ដូចផ្កាឧប្បលជាសម្បុរមានទឹកជមរលើបរលោង ។ យ៉ាងនេះហៅថា លំអសម្បុរថ្ងៃ ។

៥. **វយកល្យាណ** លំអវ័យ ស្ត្រីបរិបូណ៌ដោយលំអទោះបីប្រសូតបុត្រមួយរយដង ក៏នៅស្អាតល្អដូចជាវ័យកាលដែលមានអាយុ ១៦ឆ្នាំ ទោះបីមានអាយុមួយរយឆ្នាំហើយ ក៏នៅតែល្អស្រស់គ្រប់អវយវៈ ដូចជាស្ត្រីពេញក្រមុំ ។ យ៉ាងនេះហៅថាលំអវ័យ ។

ក្នុងកាលដែលនាងវិសាខាមានអាយុ ១៦ឆ្នាំ ថ្ងៃមួយជាថ្ងៃបុណ្យនក្ខត្តឫក្ស នាងបាននាំបរិវារតាំង៥០០ព្រមទាំងធីតារបស់សេដ្ឋីគហបតីទៅលេងទឹកក្នុងស្ទឹង។ ពេលនោះមហាមេឃបានបង្អុរភ្លៀងចុះមក ពួកធីតាៗ ទាំងប្រាយក៏នាំគ្នារត់ព្រោងព្រាតចូលទៅក្នុងសាលា ឯនាង

វិសាខា នាងដើរសន្សឹមៗ ហាក់ដូចជាមិនខ្លាចទទឹក ។ គ្រានោះមានព្រាហ្មណ៍ ៨ នាក់ជាបំរើរបស់មិគារសេដ្ឋី ដែលប្រើអោយដើររកស្រ្តីប្រកបដោយលំអ ៥ យ៉ាង ដើម្បីផ្សំផ្គុំជាភរិយាអោយបុណ្ណវឌ្ឍន៍កុមារជាកូន ។

ព្រាហ្មណ៍ ៨ នាក់ឃើញចរិយាសម្បត្តិរបស់នាងវិសាខាដូច្នោះហើយ នាំគ្នាសង្កេតពិនិត្យមើលបានដឹងជាក់ថាជាស្រ្តីប្រកបដោយលំអ ៥ យ៉ាង ប៉ុន្តែមិនទាន់ឃើញធ្មេញរបស់នាង លុះនាងវិសាខាឡើងដល់លើសាលា មានសរីរៈទទឹកជោកដោយទឹកភ្លៀង ព្រាហ្មណ៍ក៏បានឱកាសនឹងឃើញធ្មេញរបស់នាង ទើបនាំគ្នានិយាយថា ស្រ្តីនេះប្រហែលជាកូនអ្នកក្រីក្រ បានជាខ្ជិលយ៉ាងនេះ ស៊ូដើរអោយភ្លៀងទទឹកអស់ ។ នាងវិសាខាឮដូច្នោះហើយ ក៏សួរព្រាហ្មណ៍ថាអ្នកនិយាយពីអ្នកណា ? ព្រាហ្មណ៍និយាយថាយើងនិយាយពីនាង ។ ក្នុងពេលនោះនាងវិសាខាបាននិយាយប្រាប់ដល់ព្រាហ្មណ៍ ដោយសំឡេងដ៏ពីរោះ ហាក់ដូចជាសំឡេងនៃរគាំងសំរិទ្ធថា បានជាខ្ញុំមិនរត់ ស៊ូដើរអោយទទឹកគ្រឿងអលង្ការយ៉ាងនេះ ព្រោះពួកជនដែលគ្រប់លក្ខណ៍មាន ៤ពួកគឺ: **បព្វជិត ស្តេច ស្រ្តី ដំរី** ជនទាំង ៤ ពួកនេះមិនគួររត់ហើយ ព្រោះថា:

១. **បព្វជិត** ទោះបីមានហេតុយ៉ាងណា មានភ្លៀង និងខ្យល់ព្យុះជាដើម មិនត្រូវរត់ឡើយ ត្រូវតែដើរសន្សឹមៗ តាមធម្មតា ទើបហៅ

ថាបព្វជិតមានលក្ខណ៍ ។

២. **ស្តេច** ដែលបានអភិសេកហើយ កំពុងទ្រទ្រង់នូវគ្រឿងបញ្ចកុកុធភណ្ឌ ទោះបីមានហេតុយ៉ាងណា មានភ្លៀងខ្យល់ព្យុះជាដើម មិនគួររត់ដូចជាគហបតីឡើយត្រូវតែយាងសន្សឹមៗ ទើបហៅថា ស្តេចមានលក្ខណ៍ ។

៣. **ស្ត្រី** ដែលពេញក្រមុំ ទោះបីមានហេតុយ៉ាងណាមានភ្លៀងនិងខ្យល់ព្យុះជាដើម មិនត្រូវរត់ដូចជាបុរសត្រូវតែដើរសន្សឹមៗ ទើបហៅថាស្ត្រីគ្រប់លក្ខណ៍ ។

៤. **ដំរីមង្គល** ដែលគេប្រដាប់តាក់តែង ដោយគ្រឿងអលង្ការហើយ ទោះបីមានហេតុយ៉ាងណា ក៏មិនត្រូវរត់ឡើយ ត្រូវដើរដោយដំណើរធម្មតា ទើបហៅថា ដំរីមានលក្ខណ៍ ។

ព្រាហ្មណ៍ទាំង ៨ នាក់ស្តាប់ហើយ បានអោយពរសព្វសាធុការដល់នាងវិសាខា. ការចង់ឃើញនូវធ្មេញរបស់នាង ក៏បានឃើញដូចបំណង។ ព្រាហ្មណ៍ទាំង ៨ នាក់និយាយប្រាប់ដល់នាងវិសាខាថា យើងទាំងអស់គ្នាមានសេចក្តីប្រាថ្នាចំពោះនាង ហើយលើកភួងផ្កាមាសដែលមាស ដែលមានតម្លៃ ១ សែន ជូនជាគ្រឿងបុញ្ញាំចិត្តដល់នាងៗ ក៏ព្រមទទួលយកមកពាក់នូវក ដើម្បីបញ្ជាក់អោយព្រាហ្មណ៍ដឹងថា នាងព្រមទទួល ទើបនាងសួរទៅព្រាហ្មណ៍ថា អ្នកមកពីនគរណា ? ។

ព្រាហ្មណ៍ថា ខ្ញុំមកពីនគរសាវត្ថី ផ្សិតមិគារសេដ្ឋី មានកូនប្រុស ១ ឈ្មោះបុណ្ណវឌ្ឍន៍កុមារ បានបញ្ជូនខ្ញុំអោយមកដណ្តឹងនាង។

នាងវិសាខាព្រមទទួល ទើបនាំព្រាហ្មណ៍ទាំង ៨ នាក់ទៅប្រាប់ដល់ធនញ្ជយសេដ្ឋីជាបិតា ។ ធនញ្ជយសេដ្ឋីក៏ព្រម បានសួរអំពីទ្រព្យសម្បត្តិរបស់មិគារសេដ្ឋី ព្រាហ្មណ៍ប្រាប់ថាមិគារសេដ្ឋីមានប្រាក់ ៤០ កោដិ ។ ធនញ្ជយសេដ្ឋីលាន់មាត់ថាប្រាក់ ៤០កោដិនោះតិចពេកណាស់ មិនបានប្រហែលនឹងតម្លៃថែរក្សា មានតម្លៃម្សៅ និងប្រេងជាដើមរបស់កូនខ្ញុំទេ ។ ក៏តែធនញ្ជយសេដ្ឋី និងមិគារសេដ្ឋី ក៏ចាត់ចែងទៅរៀបមង្គលការបុត្រធីតា បានអញ្ជើញស្តេចទាំងពីរនគរ ព្រមទាំងគហបតីសេដ្ឋី មន្ត្រី តូចធំប្រជារាស្ត្រទាំងអស់ មកជាកិត្តិយសក្នុងមង្គលការ ។ ក្នុងថ្ងៃទី ១ ជាដំបូង ធនញ្ជយសេដ្ឋីបានហៅជាងមាស ៥០០ នាក់មកធ្វើគ្រឿង មហាលតាបសាធន៍ អាវសំរាប់ពាក់ការ ។ អាវនោះមានតំលៃ ៩ កោដិ ថ្លៃឈ្នួលជាង ១ សែនរៀល អាវនោះធ្វើអំពីមាស និងពេជ្រសុទ្ធគឺៈ

ត្បូងពេជ្រចំនួន ៤នាឡិ កែវមុក្តា ១១នាឡិ កែវបវាឡ ២២នាឡិ កែវមណី ៣៣នាឡិ ព្រមទាំងមាស និងប្រាក់ជាច្រើនយកទៅហូតធ្វើជាអំបោះ។ អាវនោះរាងជាសត្វក្ងោក ស្លាបម្ខាង១ ចំនួន ៥០០ស្លាបរចនាអំពីមាស និងប្រាក់ ចំពុះរចនាដោយកែវបវាឡ ភ្នែករចនាដោយ

កែវមណី កន្ទុយមានស្នាប ៥០០ រចនាដោយមាស និងប្រាក់។ អាវនោះ លើកពាក់ឡើងកាលណា ឃើញហាក់ដូចជាក្ងោកមាសពង់រាំឰដ៏កំពូល ភ្នំ ឮសូរសំឡេងលាន់ចេញអំពីស្នាប ដូចជាសូរដូរ្យតន្ត្រីទិព្វ។ សេដ្ឋីរៀប មង្គលការបានចំនួន ៣ ខែ ពួកអ្នកចំអិនអាហារប្រាប់ថា អស់ឧសដុត ហើយ។ សេដ្ឋីប្រាប់ថាឱ្យទៅរុះផ្ទះចាស់ៗ និងរោងដំរីយកទៅដុត ដល់ ដុតបានកន្លះខែ ក៏អស់ឧសនោះទៅទៀត ទើបសេដ្ឋីបង្គាប់ឱ្យចាក់ឃ្លាំង យកសំពត់សាច់ក្រាស់ៗ ជ្រលក់ប្រេងដុតចំអិនអាហារតទៅទៀត ដុត បានកន្លះខែទៀត ជាគំរប់ ៤ខែ។ ជាងទាំង ៥០០នាក់ ដែលធ្វើគ្រឿង មហាលតាបសាធន៍ តាំងពីថ្ងៃចូលរោងមកក៏គ្រប់ ៤ខែគត់ ទើបហើយ អាវមហាលតាបសាធន៍នោះ។ ធនញ្ជយសេដ្ឋី និងមិគារសេដ្ឋីបានផ្សំផ្គុំ នាងវិសាខា និងបុណ្ណវឌ្ឍន៍កុមារ ឱ្យជាគូស្វាមីភរិយាក្នុងថ្ងៃជាគំរប់ ៤ ខែនោះ ។

លុះរៀបអាពាហ៍ពិពាហ៍ហើយ ធនញ្ជយសេដ្ឋីបញ្ជូននាងឱ្យទៅ នៅខាងសំណាក់ម្ដាយក្មេក ឪពុកក្មេក បានចែកទ្រព្យសម្បត្តិ ឱ្យជាច្រើន គឺឱ្យភាជនៈមាស ៥០០រទេះ ភាជនៈប្រាក់ ៥០០រទេះ ភាជនៈទង់ដែង ៥០០រទេះ ភាជនៈសំរិទ្ធ ៥០០រទេះ សំពត់អំបោះ និងសំពត់សូត្រ ៥០០រទេះ សប្បិ ៥០០ រទេះ ស្ករអំពៅ ៥០០រទេះ អង្ករស្រូវសាលី គ្រឿងឧបករណ៍ផ្សេងៗ មាននង្គ័ល និងផាលជាដើម ៥០០រទេះ និងខ្ញុំ

ប្រុសស្រីជាច្រើន ។ ក្នុងថ្ងៃដែលនាងចេញទៅ បានបង្គាប់ឱ្យបុរស បុរសបើកទ្វារក្រោលគោ ហើយឱ្យដេញគោចេញទៅវាលបណ្តាយបី ល្បីស្តរទទឹង ៣ ឧសភៈ បុរសក៏ធ្វើតាមបង្គាប់របស់សេដ្ឋី លុះគ្រប់ចំនួន ហើយ បុរសបិទទ្វារក្រោល គោក៏ស្ទុះទម្លាយក្រោលទៅតាមនាងទៀត ដោយផលបុណ្យដែលនាងបានធ្វើទានដោយចិត្តទូលាយពីជាតិមុនមក ។ ថ្ងៃមួយនាងវិសាខាទៅស្តាប់ធម៌នៅវត្តជេតពន បាននាំកូន និងចៅជា ច្រើនពាន់ទៅជាមួយផង កាលនោះមានភិក្ខុមួយរូបចង់ឃើញនាង វិសាខា បានសួរភិក្ខុមួយរូបដែលអង្គុយជិត ភិក្ខុនោះប្រាប់ថា មើលតែ ស្រីណា ក្រោកឡើងយកដៃច្រត់ក្បាលជង្គង់ ស្រីនោះហើយ គឺនាង វិសាខា ។

កាលនោះនាងវិសាខាមានអាយុ ៧០ឆ្នាំហើយ នាងនៅតែក្មេង ដូចជាចៅរបស់នាង ដែលមានអាយុ ១៦ ឆ្នាំ។ នាងវិសាខាមានកូន ២០ ក្នុងកូនមួយៗ មានចៅ ២០ ក្នុងចៅមួយៗ មានកូន ២០ រួមទាំងអស់ មានចៅ ទាំងចៅទួតចំនួន ៨៤២០នាក់ ឥតមានឈឺស្លាប់មួយឡើយ ។ នាងវិសាខាមានកម្លាំងស្មើកម្លាំងដំរី ៥ ថ្ងៃមួយនាងត្រឡប់មកពីស្តាប់ ធម៌ ព្រះរាជាចង់ល្បងកម្លាំងរបស់នាងបានលែងដំរីចុះប្រេង ១ ឱ្យទៅ ព្រួជ្ឈនាង១ បានយកម្រាមដៃពីរទប់ដំរី១ ក៏ដួលក្រាបលើផែនដី មិន អាចក្រោកបានឡើយ ។ ថ្ងៃមួយនាងវិសាខាទៅស្តាប់ធម៌ដោះគ្រឿង

មហាលតាបសាធន៍ ទុកខាងក្រៅវិហារ ដល់ស្ដាប់ធម៌ហើយ ក៏ភ្លេចចោលនៅទីនោះ ទើបប្រើនាងទាសីដែលមានកម្លាំងស្មើនឹងនាងឱ្យទៅយកអាវ បានប្រាប់ថា បើភិក្ខុអង្គណា លោករើសបានទុកប្រគេនលោកចុះ កុំយកមកវិញ ។

ពេលនោះព្រះអានន្ទបានរើសទុក ព្រោះលោកមានកម្លាំងលើកអាវនោះរួច។ តម្លៃអាវនេះហើយ ដែលកសាងបានវត្តបុព្វារាមមួយ។ នាងវិសាខាមានអាយុ ១២០ឆ្នាំ នាងធ្វើមរណកាលទៅ បានទៅកើតក្នុងស្ថាននិម្មានរតី ជាអគ្គមហេសីរបស់ព្រះបាទនិម្មាតទេវបុត្រ ។

ធម៌ទេសនា ដែលខ្ញុំព្រះករុណា អាត្មាភាព បានសំដែងអំពីបុណ្យកឋិនទាន ក៏បញ្ចប់តែត្រឹមប៉ុណ្ណេះ ដ៏សមគួរដល់កាល និងវេលា តែមុននឹងបញ្ចប់សូមឧទ្ទិសឥដ្ឋមនុញ្ញផល ដែលកើតអំពីការបំពេញនូវបុញ្ញកិរិយាវត្ថុនេះ ដល់ពពួកទេវតា ក្នុងសែនកោដិចក្កវាឡ និងសូមឧទ្ទិសជូន វិញ្ញាណក្ខន្ធ នៃបុព្វការីជន គឺមាតាបិតា គ្រូឧបជ្ឈាយាចារ្យ ញាតិកា សាច់សាលោហិត ដែលបានទម្លុះកាយទម្លាយខន្ធ ទៅកាន់បរលោកហើយ និងវិញ្ញាណក្ខន្ធ កម្មាភិបាល យុទ្ធជន យុទ្ធនារី ដែលបានពលីជីវិត ដើម្បីប្រទេសជាតិ មាតុភូមិ ។

**យំ យំ ឥច្ឆិតំ តំ តំ ខិប្បមេវ សមិជ្ឈតុ** ព្រះករុណាគ្រប់ព្រះអង្គ និងពុទ្ធបរិស័ទទាំងឡាយ មានសេចក្ដីប្រាថ្នា ហើយ

យ៉ាងណាៗ សូមឱ្យបានសំរេចយ៉ាងនោះ ៗ កុំបីឃ្លៀងឃ្លាតឡើយ ។

អយំ សង្ខេបេន កឋិនធម្មទេសនា និដ្ឋិតា ធម្មទេសនា ដែលបានសម្តែង អំពីពាក្យថាកឋិនក៏សន្មតថាចប់តែប៉ុណ្ណេះ ឯវំ ។

ម៊ឹន ឈោ. រស់ វ៉េត.

កំពង់ស្ពឺ.